# គន្លឹះសំខាន់ៗដើម្បី
# បណ្តុះទម្លាប់អានសិស្សបឋមសិក្សា

## ១. សេចក្តីផ្តើម

ទម្លាប់អានមានសារៈសំខាន់សម្រាប់មនុស្សគ្រប់រូប គ្រប់វ័យ ។ កុមារមានទម្លាប់អាន ជាកុមារ ដែលអានច្រើនទាំងក្នុង និងក្រៅម៉ោងបណ្ណាល័យនិងពេលទំនេរ ។ ឆ្លងតាមបទពិសោធន៍លើការងារពង្រឹងទម្លាប់អានសិស្សបឋមសិក្សា រូមធូរីដបានចងក្រងឯកសារនេះ ដើម្បីពង្រីកការអនុវត្តន៍ក្នុងគោលបំណងឱ្យកុមារមានទម្លាប់អានកាន់តែច្រើន ។

## ២. គន្លឹះសំខាន់ៗដើម្បីបណ្តុះទម្លាប់អាន

គន្លឹះសំខាន់ៗដើម្បីបណ្តុះទម្លាប់អាននេះ បានអនុវត្តន៍ប្រកបដោយជោគជ័យនៅសាលាបឋមសិក្សាដែលគាំទ្រដោយរូមធូរីដរួចហើយ ។ គន្លឹះទាំងនេះ មិនទាមទារការជួយគាំទ្រខ្លាំងក្លាពីរូមធូរីដនោះទេ ។ គន្លឹះទាំងនោះរួមមាន ៖

1. រៀបចំបណ្ណាល័យឱ្យក្លាយជាទីមេត្រីសម្រាប់កុមារ
2. បែងចែកឱ្យមានម៉ោងបណ្ណាល័យឬម៉ោងសម្រាប់អានជាផ្លូវការ
3. បំប៉នគ្រូទាំងអស់ឱ្យចេះដឹកនាំសកម្មភាពអំណានបែបលើកទឹកចិត្តសិស្សនិងស្រលាញ់សៀវភៅ
4. ចងក្រងសម្ភារៈ ព្រីនរីដ (Print Rich) រួចដាក់តាំងបង្ហាញក្នុងបណ្ណាល័យនិងដោះដូរជាប្រចាំ ។

### ២-១- ការរៀបចំបណ្ណាល័យឱ្យក្លាយជាទីមេត្រីសម្រាប់កុមារ

បណ្ណាល័យបែបកុមារមេត្រីជាទីកន្លែង ដែលកុមារអាចអាន និង ចូលរួមសកម្មភាពអំណានផ្សេងៗប្រកបដោយភាពកក់ក្តៅ និងមានការជួយគាំទ្រពីមនុស្សធំ ។ ជាកន្លែងដែល មានបរិយាកាសមួយមិនមានការបង្ខិតបង្ខំ ការគំរាមកំហែងឬភ័យខ្លាចអ្វីឡើយ ។ បណ្ណារក្ស លោកគ្រូ អ្នកគ្រូ នាយកសាលា មាតាបិតា និងសហគមន៍ ជួយគាំទ្រយ៉ាងសកម្មក្នុងការជំរុញលើកទឹកចិត្ត និង ចូលរួមជាមួយកុមារក្នុងការអានប្រកបដោយភាពសប្បាយរីករាយនិងស្និទ្ធស្នាល ។ ដើម្បីឱ្យបណ្ណាល័យក្លាយជាទីមេត្រីសម្រាប់កុមារ សាលារៀនត្រូវរៀបចំបណ្ណាល័យដូចខាងក្រោម ៖

- ត្រូវបែងចែកសៀវភៅអានគ្រប់ប្រភេទតាមកម្រិតអានរបស់សិស្ស ដោយមានបិតលេខកូដ
- ត្រូវតាំងសៀវភៅកម្រិតទាបនៅថ្នាក់ក្រោមនៃធ្នើរ ដើម្បីសិស្សងាយស្រួលស្វែងរក
- ត្រូវរៀបគ្រឿងសង្ហារិមឱ្យមានចន្លោះ ដើម្បីសិស្សងាយរកសៀវភៅ និង មានកន្លែងអង្គុយអាន
- ត្រូវមានបណ្ណារក្សឬគ្រូ ទទួលខុសត្រូវគ្រប់គ្រងបណ្ណាល័យ (ខ្ចី សង ជួយសិស្សរកសៀវភៅ)
- ត្រូវមានកាលវិភាគម៉ោងបណ្ណាល័យសម្រាប់សិស្សគ្រប់ថ្នាក់តាំងបង្ហាញនិងអនុវត្តជាប្រចាំ
- ត្រូវឱ្យគ្រូបន្ទុកថ្នាក់នាំសិស្សមកធ្វើសកម្មភាពអាននៅម៉ោងបណ្ណាល័យតាមកាលវិភាគ

- ត្រូវតាំងបង្ហាញ**សម្ភារៈព្រិនរីជ**លើជញ្ជាំង ឬ ខ្សែ ក្នុងបណ្ណាល័យ ។

## ២-២- របៀបបែងចែកម៉ោងបណ្ណាល័យឬម៉ោងសម្រាប់អាន

នាយកសាលា ត្រូវបែងចែកម៉ោងភាសាខ្មែរ១ម៉ោងក្នុងមួយសប្តាហ៍ ឱ្យសិស្សតាមថ្នាក់នីមួយៗបានចូលបណ្ណាល័យជាផ្លូវការតាមតារាងដូចខាងក្រោម ៖

| ថ្នាក់ទី | ម៉ោងបង្រៀនភាសាខ្មែរ | ម៉ោងចូលបណ្ណាល័យ |
|---|---|---|
| ថ្នាក់ទី១-៣ | ១៣ ម៉ោង/សប្តាហ៍ | ១ ម៉ោង/១ថ្នាក់/សប្តាហ៍ |
| ថ្នាក់ទី ៤ | ១០ ម៉ោង/សប្តាហ៍ | ១ ម៉ោង/១ថ្នាក់/សប្តាហ៍ |
| ថ្នាក់ទី ៥-៦ | ៨ ម៉ោង/សប្តាហ៍ | ១ ម៉ោង/១ថ្នាក់/សប្តាហ៍ |


កាលវិភាគបណ្ណាល័យប្រចាំសប្តាហ៍ទី..............

ប្រចាំខែ.................ឆ្នាំសិក្សា 2015-2016

| ម៉ោងសិក្សា | ច័ន្ទ | អង្គារ | ពុធ | ព្រហស្បតិ៍ | សុក្រ | សៅរ៍ |
|---|---|---|---|---|---|---|
| ទី ១ | អនាម័យ | អនាម័យ | អនាម័យ | អនាម័យ | អនាម័យ | អនាម័យ |
| ចេញលេង (១០ នាទី) | អំណានសេរី | អំណានសេរី | អំណានសេរី | អំណានសេរី | អំណានសេរី | អំណានសេរី |
| ទី ២ ព្រឹក / រសៀល | ម.ត / ថ្នាក់ទី 2 | ថ្នាក់ទី 1 ក / ថ្នាក់ទី 3 | ថ្នាក់ទី 1 ខ | | ថ្នាក់ទី 6 | ថ្នាក់ទី 4 |
| ចេញលេង (១០ នាទី) | អំណានសេរី | អំណានសេរី | អំណានសេរី | អំណានសេរី | អំណានសេរី | អំណានសេរី |
| ទី ៣ ព្រឹក / រសៀល | | | | | | |
| ចេញលេង (១០ នាទី) | អំណានសេរី | អំណានសេរី | អំណានសេរី | អំណានសេរី | អំណានសេរី | អំណានសេរី |
| ទី ៤ ព្រឹក / រសៀល | | | | | | |
| ចេញលេង (១០ នាទី) | អំណានសេរី | អំណានសេរី | អំណានសេរី | អំណានសេរី | អំណានសេរី | អំណានសេរី |
| ទី ៥ | | | | | | |

កាលវិភាគនេះ អនុវត្តស្របគ្នានឹងកាលវិភាគសិក្សារបស់នាយកដ្ឋានបឋម និងមត្តេយ្យសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៩៩ ដែលតម្រូវឱ្យគ្រឹះស្ថានបឋមសិក្សាអនុវត្តដូចតទៅ : ☞ ១ ម៉ោងសិក្សា = ៤០ នាទី និង ☞ ម៉ោងចេញលេង ១ ដង = ១០ នាទី

## ២-៣- សកម្មភាពអំណានបែបលើកទឹកចិត្តសិស្សនិងស្រលាញ់សៀវភៅ

ជាទូទៅ សកម្មភាពអំណានបែបលើកទឹកចិត្តសិស្សនិងស្រលាញ់សៀវភៅនេះ មានច្រើន ។ ប៉ុន្តែតាមបទពិសោធន៍អនុវត្តន៍ជាក់ស្តែង រូមធ្មរីដរកឃើញសកម្មភាពអំណាន៤ ដែលមានការទាក់ទាញសិស្សឱ្យអានសៀវភៅបានច្រើន ហើយគ្រូងាយអនុវត្តថែមទៀត ។ សកម្មភាពអំណានទាំង៤នោះរួមមាន៖

**ក - <u>អំណានឮ</u>៖** មានគោលបំណងឱ្យសិស្សដឹងពីរបៀបអានសៀវភៅ ចេះស្តាប់ និង យល់ខ្លឹមសារក្នុងសៀវភៅ ។ គ្រូត្រូវជ្រើសរើសសៀវភៅអានឱ្យខ្ពស់ជាងកម្រិតអានរបស់សិស្សមកអានឱ្យសិស្សស្តាប់ ។ រយៈពេលនៃការអានគឺចន្លោះពី ២០ ទៅ៣៥នាទី ។

# របៀបដឹកនាំសកម្មភាពអំណានឮ

❖ **មុនពេលអាន (រយៈពេលសកម្មភាព ៥ – ១០នាទី)**

បណ្ណារក្ស ឬគ្រូត្រូវធ្វើ៖

- ជ្រើសរើសសៀវភៅ ដែលលើសពីកម្រិតសមត្ថភាពអានរបស់សិស្ស ប៉ុន្តែសិស្សអាចយល់បាន ។ បន្ទាប់មក រៀបចំឱ្យសិស្សអង្គុយជិតគ្រូ ដើម្បីងាយមើល និង ងាយស្តាប់បាន
- បង្ហាញរូបភាពនិងចំណងជើងលើក្របសៀវភៅ ហើយឱ្យសិស្សទស្សន៍ទាយរឿង
- សួរឬប្រាប់សិស្សពីឈ្មោះអ្នកនិពន្ធ
- សួរសំណួរផ្សេងៗដោយភ្ជាប់រូបភាពទៅនឹងជីវភាពប្រចាំថ្ងៃរបស់សិស្ស ។ **ឧទាហរណ៍៖** តើមានរូបភាព ឬសត្វអ្វីខ្លះ ដែលប្អូនបានឃើញ? តើរូបភាព ឬសត្វនេះមានពណ៌អ្វីខ្លះ? តើប្អូនធ្លាប់ជួបប្រទះ រូបភាព ឬសត្វនេះនៅទីកន្លែងណាខ្លះ? តើផ្ទះប្អូនមានរូបភាព ឬសត្វនេះទេ?

❖ **អំឡុងពេលអាន (រយៈពេលសកម្មភាព ១០– ១៥នាទី)**

បណ្ណារក្ស ឬគ្រូ៖

- ត្រូវអានរឿងនោះឮៗឱ្យសិស្សស្តាប់ដោយលើកដាក់សំឡេង ធ្វើកាយវិការ និងទឹកមុខតាមតួអង្គ ធ្វើយ៉ាងណាឱ្យកុមារចាប់អារម្មណ៍
- អំឡុងពេលអាន ត្រូវផ្អាកត្រង់ចំណុចសំខាន់ៗមួយចំនួន រួចសួរមួយឬពីរសំណួរ អំពីសាច់រឿងនោះ ដើម្បីឱ្យប្រាកដថា សិស្សយល់អំពីអត្ថន័យនៅក្នុងសៀវភៅ (ការផ្អាកគួរធ្វើតែ ២ទៅ៣ដងបានហើយ)។ ឧទាហរណ៍៖ តើប្អូនគិតថា នឹងមានអ្វីកើតឡើងបន្ទាប់មកទៀត?

❖ **ក្រោយពេលអាន (រយៈពេលសកម្មភាព ៥ - ១០នាទី)**

- សួរសិស្សអំពីសាច់រឿង ដើម្បីជំរុញនិងលើកទឹកចិត្តគេឱ្យបញ្ចេញមតិយោបល់ និងបង្កើនការយល់ដឹងបន្ថែមទៀត ។ ឧទាហរណ៍៖
    - តើរឿងនេះ កើតឡើងនៅឯណា?
    - តើនរណាខ្លះ ជាតួអង្គសំខាន់ៗ? តើរឿងនេះមានតួអង្គប៉ុន្មាននាក់?
    - តើតួអង្គណាខ្លះ ដែលប្អូនចូលចិត្តជាងគេ? ហេតុអ្វី?

**ខ. <u>អំណានចូលរួម</u>៖** គោលបំណង ឱ្យសិស្សចូលរួមយ៉ាងសកម្មក្នុងការអានសៀវភៅ បង្កភាពរីករាយជាមួយនឹងរូបភាពផ្សេងៗ និងពាក្យពេចន៍នៅក្នុងរឿង ។ គ្រូត្រូវជ្រើសរើសសៀវភៅប្រហាក់ប្រហែលនឹងកម្រិតអានរបស់សិស្ស ។ សកម្មភាពអំណានចូលរួមនេះប្រើរយៈពេលចន្លោះពី២០ - ៣៥នាទី ។

## **ដំណើរការសកម្មភាពអំណានចូលរួម**

បណ្ណារក្សឬគ្រូ ត្រូវអានរឿងនោះ**ចំនួនពីរលើក** ។ ខាងក្រោមនេះ បង្ហាញពីរបៀបអានទាំងពីរលើក ។

**ការអានលើកទីមួយ**

❖ **មុនពេលអាន (រយៈពេលសកម្មភាព ៥ – ១០នាទី)**

បណ្ណារក្ស ឬគ្រូត្រូវ៖

- ជ្រើសរើសសៀវភៅស្របតាមកម្រិតអានរបស់សិស្ស រួចឱ្យសិស្សអង្គុយជិតគ្រូដើម្បីអាចឃើញអត្ថបទ និងរូបភាព
- បង្ហាញសិស្សនូវរូបភាពនិងចំណងជើងលើក្របសៀវភៅ ហើយឱ្យសិស្សទស្សន៍ទាយ តើរឿងនេះនិយាយពីអ្វី? សួរ ឬប្រាប់សិស្សពីឈ្មោះអ្នកនិពន្ធ
- កាន់សៀវភៅយ៉ាងណាឱ្យសិស្សទាំងអស់អាចមើលឃើញ រួចបើកទំព័រទី១ ។ ដោយសាររូបភាពនៅទំព័រទី១ តែងតែផ្តល់តម្រុយសាច់រឿង ដូច្នេះគ្រូឬបណ្ណារក្សគួរឈប់ត្រង់ទំព័រនេះ រួចឱ្យសិស្សទស្សន៍ទាយខ្លឹមសារសាច់រឿង (ឧទាហរណ៍៖ តើប្អូនៗគិតថារឿងនេះកើតនៅឯណា?)
- សួរសំណួរផ្សេងៗដោយភ្ជាប់រូបភាពទៅនឹងជីវភាពប្រចាំថ្ងៃរបស់កុមារ ។ ឧទាហរណ៍ តើមានរូបភាព ឬសត្វអ្វីខ្លះដែលប្អូនបានឃើញ? តើរូបភាព ឬសត្វនេះមានពណ៌អ្វីខ្លះ? តើប្អូនធ្លាប់ជួបប្រទះ រូបភាព ឬសត្វនេះនៅទីកន្លែងណាខ្លះ? តើផ្ទះប្អូនមានរូបភាព ឬសត្វនេះទេ?

❖ **អំឡុងពេលអាន (រយៈពេលសកម្មភាព ១០ – ១៥នាទី)**

- អំឡុងពេលអាន គ្រូត្រូវកាន់សៀវភៅយ៉ាងណាឱ្យសិស្សទាំងអស់អាចមើលឃើញអត្ថបទនិងរូបភាព
- គ្រូចាប់ផ្តើមអានរឿងឮៗ ដោយមានការលើកដាក់សំឡេង ធ្វើទឹកមុខនិងកាយវិការទៅតាមតួអង្គក្នុងសាច់រឿង ។ គ្រូត្រូវបញ្ចេញសំឡេងច្បាស់តាមពាក្យនីមួយៗ និងប្រើប្រាស់វណ្ណយុត្តិ ដើម្បីជួយសង្កត់អត្ថន័យរបស់អត្ថបទ ។
- ដើម្បីចង់ដឹងពីការយល់សាច់រឿងរបស់សិស្ស គ្រូត្រូវផ្អាកអានខ្លះៗ រួចសួរសំណួរងាយៗឱ្យសិស្សទស្សន៍ទាយ ។ ឧទាហរណ៍៖ តើប្អូនគិតថានឹងមានអ្វីកើតឡើងបន្ទាប់ទៅទៀត?

❖ **ក្រោយពេលអាន (រយៈពេលសកម្មភាព ៥ – ១០នាទី)**

- គ្រូអាចសួរសំណួរងាយៗតាមកម្រិតយល់ដឹងរបស់សិស្សដូចខាងក្រោម៖
  - តើរឿងនេះមានតួអង្គណាខ្លះ?
  - តើតួអង្គណាដែលប្អូនចូលចិត្តជាងគេ? ហេតុអ្វី?
  - តើរឿងនេះកើតឡើងនៅកន្លែងណា?
  - តើរឿងនេះកើតឡើងនៅពេលណា?
- ពេលអានរឿងលើកទីមួយចប់ហើយគ្រូវលើកទឹកចិត្តសិស្សឱ្យ**ចូលរួមអានរឿងនោះជាមួយគ្រូលើកទីពីរ** ។ គ្រូមិនត្រូវបង្ខំសិស្សឱ្យអានទេ បើសិស្សនោះមិនចង់អាន ។

**<u>ការអានលើកទីពីរ</u>**

- មុនពេលអាន គ្រូត្រូវលើកទឹកចិត្តសិស្សឱ្យអានជាមួយគ្នាតាមជម្រើសដូចខាងក្រោម៖
  - ✓ អានពាក្យ ឬឃ្លាដែលសិស្សចាប់អារម្មណ៍
  - ✓ អានពាក្យ ឬឃ្លាដដែលៗ
  - ✓ ត្រាប់សំឡេងតាមតួអង្គ
  - ✓ ធ្វើសកម្មភាពដែលទាក់ទាញផ្សេងៗនៅក្នុងរឿង ។
- បន្ទាប់មកគ្រូត្រូវអានឮៗនិងចង្អុលតាមឃ្លានីមួយៗដោយយឺតៗ រីឯសិស្សចូលរួមសកម្មភាពដូចខាងលើជាមួយគ្រូក្នុងពេលតែមួយ។

**<u>គ. អំណានដៃគូ៖</u>** មានគោលបំណងឱ្យសិស្ស អាចជួយគ្នាទៅវិញទៅមក លើការអានពាក្យថ្មី ឬពាក្យពិបាក ។ សិស្សដៃគូអាចមានកម្រិតអានដូចគ្នា ឬប្រហាក់ប្រហែលគ្នា ដែលអាចជួយគ្នាក្នុងការអានបាន ។ ដៃគូសិស្សនីមួយៗ មានសៀវភៅរឿងមួយក្បាល ដែលសមស្របទៅនឹងកម្រិតអានរបស់ពួកគេ ។ រយៈពេលសកម្មភាពពី ២០-៤០នាទី

## <u>ដំណើរការសកម្មភាពអំណានដៃគូ</u>

- ❖ **មុនពេលអាន (រយៈពេលសកម្មភាព៥-១០នាទី)**
  - គ្រូរៀបចំដៃគូសិស្ស ឬឱ្យសិស្សជ្រើសរើសដៃគូដោយខ្លួនឯង ។ ដៃគូនីមួយៗជ្រើសរើសសៀវភៅមួយក្បាល ដែលសមស្របនឹងកម្រិតអានរបស់ពួកគេ ។ សៀវភៅនោះអាចជាសៀវភៅរឿងនិទាន រឿងខ្លី កំណាព្យ សៀវភៅព័ត៌មាន ឬសៀវភៅសិក្សាគោល ។ ប្រសិនបើពួកគេមិនដឹងពីកម្រិតអានរបស់ខ្លួន គ្រូត្រូវជួយចង្អុលបង្ហាញសៀវភៅ ដែលសមស្របនឹងកម្រិតអានពួកគេ ។
  - គ្រូណែនាំទៅដៃគូសិស្សឱ្យជួយគ្នាដូចជា អានមួយទំព័រ ឬមួយកថាខណ្ឌម្តងម្នាក់ ។
- ❖ **អំឡុងពេលអាន (រយៈពេលសកម្មភាព១០-២០នាទី)**
  - គ្រូឱ្យសិស្សរកកន្លែងសមស្របដើម្បីអានជាដៃគូ ។ ពេលសិស្សកំពុងអានគ្រូ ត្រូវដើរពិនិត្យមើលនិងជួយកុមារក្នុងការអាន ។
  - គ្រូអាចអានអត្ថបទជាមួយសិស្ស ឬពេលខ្លះពិនិត្យមើលដៃគូផ្សេងទៀត ថាតើពួកគេជ្រើសរើសសៀវភៅត្រូវនឹងកម្រិតអានហើយឬនៅ?
- ❖ **ក្រោយពេលអាន (រយៈពេលសកម្មភាព៥-១០នាទី)**

  គ្រូឱ្យដៃគូនីមួយៗ ចូលក្រុមធំវិញ ហើយជ្រើសរើសយកសកម្មភាពដូចខាងក្រោម៖
  - ចែករំលែក/និយាយបង្ហាញពីផ្នែកណាមួយដែលពួកគេចូលចិត្ត ឬមិនចូលចិត្តនៅក្នុងសាច់រឿង
  - សង្ខេបរឿងដោយប្រើភាសាផ្ទាល់ខ្លួនជាក្រុម ឬជាបុគ្គល
  - គូររូបត្រង់ផ្នែកណាមួយដែលចូលចិត្ត។

**ឃ- <u>អំណានបុគ្គល៖</u>** គោលបំណងឱ្យសិស្ស អាចអានសៀវភៅបានស្របតាមកម្រិតអានរបស់ពួកគេ និងជ្រើសរើសសៀវភៅតាមអ្វីដែលពួកគេចង់អាន ។ រយៈពេលសកម្មភាពនេះគឺចន្លោះពី២០ទៅ៤០នាទី

## **ដំណើរការសកម្មភាពអំណានបុគ្គល**

- ❖ **មុនពេលអាន (រយៈពេលសកម្មភាព ៥ – ១០នាទី)**

គ្រូឱ្យសិស្សម្នាក់ៗ ជ្រើសរើសសៀវភៅស្របតាមកម្រិតអានរបស់ពួកគេ អាចជាសៀវភៅរឿង រឿងខ្លីៗ កំណាព្យ សៀវភៅព័ត៌មាន ឬសៀវភៅសិក្សាគោល ។

- ❖ **អំឡុងពេលអាន (រយៈពេលសកម្មភាព ១០ – ២០នាទី)**
  - គ្រូណែនាំសិស្ស ឱ្យរកកន្លែងសមស្របណាមួយ សម្រាប់អាន
  - គ្រូដើរជួយសម្របសម្រួលដល់សិស្ស លើពាក្យឬឃ្លាណាដែលពិបាកៗ ឬឱ្យសិស្សដូរសៀវភៅឱ្យស្របទៅនឹងកម្រិតអានរបស់ពួកគេ។
- ❖ **ក្រោយពេលអាន (រយៈពេលសកម្មភាព ៥– ១០នាទី)**

គ្រូឱ្យសិស្សចែករំលែកគ្នាពីអ្វីដែលពួកគេបានអាន ។ កុមារអាចធ្វើការចែករំលែកតាមរយៈ ៖

- ការនិយាយរឿងឡើងវិញតាមភាសាពួកគេផ្ទាល់ ជាក្រុម ឬជាបុគ្គល
- ជ្រើសរើសផ្នែកណាមួយនៃសាច់រឿងដែលពួកគេចូលចិត្ត និងបញ្ជាក់អំពីហេតុផលឬគូររូបភាពអំពីផ្នែកណាមួយនៃសាច់រឿងជាដើម ។

### **២-៤- ការរៀបចងក្រងសម្ភារៈព្រីនរីជ** (Print Rich)

ព្រីនរីជគឺជាអត្ថបទសំណេរដោយដៃឬបោះពុម្ព ឬសម្ភារៈ ឬរូបភាព ដែលមានអក្សរ សម្រាប់ដាក់តាំងបង្ហាញក្នុងបណ្ណាល័យ ដើម្បីទាក់ទាញសិស្សឱ្យមានចំណាប់អារម្មណ៍អាន ។ អត្ថបទនិងសម្ភារៈទាំងនោះអាចជា៖

- អត្ថបទ ឬស្នាដៃផ្សេងៗដែលសរសេរ ឬធ្វើដោយសិស្ស
- អត្ថបទដែលពិពណ៌នាដោយសិស្ស ហើយកត់ត្រាដោយគ្រូ ឬបណ្ណារក្ស
- ផ្ទាំងរូបភាពមានអក្សរ និងសម្ភារៈបោះពុម្ពផ្សេងៗដែលសិស្សអាចអានបាន ។

ជាទូទៅសម្ភារៈព្រីនរីជទាំងនោះ ត្រូវសមស្របទៅនឹងកម្រិតអានរបស់សិស្ស ។ ជារួមសិស្ស**អាចអាននិងយល់**ពីខ្លឹមសារ ដែលតាំងបង្ហាញ ។ ព្រីនរីជត្រូវការ **ផ្លាស់ប្តូរជាប្រចាំ** ដើម្បីទាញចំណាប់អារម្មណ៍របស់សិស្ស ។ ដូច្នេះ ព្រីនរីជមិនមែនជាសម្ភារៈសម្រាប់ "តាំងលម្អ" នោះទេ ។

## **របៀបបង្កើតសម្ភារៈព្រីនរីជ**

- ❖ **មុនពេលបង្កើត**
  - ចងខ្សែសន្ទឹងឱ្យតឹងស្របនឹងជញ្ជាំងខាងក្រោយ ឬចំហៀង សម្រាប់តាំងសម្ភារៈព្រីនរីជ
  - លើកទឹកចិត្តសិស្សឱ្យបង្កើតព្រីនរីជ បន្ទាប់ពីគ្រូធ្វើសកម្មភាពអំណានរួច
  - ចែកក្រដាស A4 ឱ្យសិស្ស
  - គ្រូបត់ក្រដាសជាគំរូបង្ហាញសិស្សដោយ៖
    - ✓ កាន់ក្រដាសក្នុងទម្រង់បញ្ឈរ ហើយឱ្យសិស្សធ្វើតាម
    - ✓ បត់ក្រដាសគែមខាងឆ្វេងចូលទំហំ ២.៥ ស.ម

- ✓ បត់ក្រដាសផ្នែកខាងលើចូលក្នុងទំហំ ២.៥ ស.ម
- ✓ ណែនាំសិស្សឱ្យគូរ ឬសរសេរនៅលើផ្នែកដែលនៅសល់ ។

❖ **អំឡុងពេលបង្កើត**

- សិស្សចាប់ផ្ដើមគូរពីតួអង្គ ឬផ្នែកនៃសាច់រឿងដែលពួកគេចូលចិត្ត (រឿងដែលទើបអានរួច)
- សិស្សសរសេរអក្សរធំៗមួយ ឬពីរប្រយោគខាងក្រោមរូបភាពនោះដោយបង្ហាញហេតុផលដែលពួកគេចូលចិត្តតួអង្គនោះ
- សិស្សសរសេរឈ្មោះខ្លួនឯង និងថ្នាក់នៅជ្រុងខាងឆ្វេងផ្នែកខាងលើនៃក្រដាស
- បណ្ណារក្ស គ្រូ ឬសិស្សដទៃទៀតជួយពិនិត្យអក្ខរាវិរុទ្ធ
- បណ្ណារក្ស ឬគ្រូជួយណែនាំសិស្សពេលពួកគេធ្វើកិច្ចការ។

❖ **ក្រោយពេលបង្កើត**

- ស្នាដៃសិស្សទាំងអស់ត្រូវដាក់តាំងបង្ហាញដោយព្យួរតាមខ្សែចងត្រង់ផ្នត់ទទឹងដែលបានបត់រួច
- ស្នាដៃទាំងនោះត្រូវធ្វើការផ្លាស់ប្ដូររាល់សប្ដាហ៍ ខែ ឬត្រីមាស
- ស្នាដៃដែលបានផ្លាស់ប្ដូរត្រូវទុកតាមថ្នាក់ រួចកិបជាឯកសារសម្រាប់សិស្សម្នាក់ៗ ហើយចែកឱ្យពួកគេនៅចុងឆ្នាំសិក្សានីមួយៗ ។